# មិនមានអញ ក្នុងខន្ធប្រាំ

| | |
|---|---|
| យើងសំគាល់រូបថារូបអញ | វេទនា សញ្ញា អញដែរ |
| សង្ខារ វិញ្ញាណ អញហូរហែ | អ្វីៗអញដែរ អញទាំងអស់។ |
| បើវែកញែកមើលនៅក្នុងខ្លួន | មិនឃើញមានអ្វីជាអញសោះ |
| ឃើញដីទឹកភ្លើងខ្យល់ប៉ុណ្ណោះ | មិនឃើញអញសោះនៅត្រង់ណា។ |
| វេទនា ដឹងសោយសុខទុក្ខ | គ្រប់មុខពល់រូបពល់អាត្មា |
| ផ្សំគ្នាកើតឡើងតាមហេតុការណ៍ | គ្មានអញអត្តាគួរអោឡោះ ។ |
| ចំណែក សញ្ញាកត់ចំណាំ | ចាំរូបសម្លេង ទាប និង ខ្ពស់ |
| ខ្មៅ ស វែង ខ្លីអ្វីទាំងអស់ | ក្នុងនោះក៏គ្មានអត្តាដែរ ។ |
| សង្ខារតាក់តែងផ្សំផ្គុំគិត | កើតជាគំនិតច្រើនឥតល្ហែ |
| បាបបុណ្យគុណទោសពល់ថ្ងៃខែ | ក្នុងនោះក៏ដែរគ្មានអញទៀត។ |
| វិញ្ញាណឃើញរូបឮសម្លេង | ធុំក្លិនផ្សេងៗភ្លក្សរសជាតិ |
| រឹងទន់ត្រជាក់ក្ដៅប៉ះបៀត | ក្នុងនោះក៏ទៀតគ្មានអញឡើយ។ |
| យើងជឿប្រកាន់ស្មានតាមគ្នា | អស់ពេលវេលាមកយូរហើយ |
| កើតទុក្ខតានតឹងចិត្តឥតស្បើយ | អ្នកកើយឈប់ជឿខុសទៀតទៅ៕ |

**ចាកទុក្ខកើតព្រោះអញ ឆ្នាំ ២០០០**

| | |
|---|---|
| **អត្តា ហិ អត្តនោ នាថោ** | **កោ ហិ នាថោ បរោ សិយា** |
| **អត្តនា ហិ សុទន្តេន** | **នាថំ លភតិ ទុល្លភំ ។** |
| ត្រូវយកខ្លួនឯងជាទីពឹង | ពឹងជនដទៃបានពីណា |
| ទូន្មានខ្លួនបានល្អថ្លៃថ្លា | បានជាពំនឹងពឹងក្រក្រៃ ។ |